# របៀបបោះឆ្នោត

**VOTE 2022**

សន្លឹកឆ្នោតរបស់អ្នកគឺជាសំឡេងរបស់អ្នក-សូមទៅចុះឈ្មោះបោះឆ្នោត ទទួលព័ត៌មាន និងសូមអញ្ជើញទៅបោះឆ្នោត!

## តើនរណាខ្លះមានសិទ្ធិបោះឆ្នោត?

ដើម្បីបោះឆ្នោតនៅរដ្ឋ Minnesota អ្នកត្រូវតែជា ពលរដ្ឋអាមេរិកដែលមានអាយុយ៉ាងតិច18ឆ្នាំនៅថ្ងៃ បោះឆ្នោត ហើយជាពលរដ្ឋនៃរដ្ឋ Minnesota យ៉ាងតិច20ថ្ងៃ។

ប្រសិនបើអ្នកត្រូវបានកាត់ឱ្យជាប់ទោសឧក្រិដ្ឋ អ្នកអាចបោះឆ្នោតនៅក្រោយពីអ្នកបញ្ចប់គ្រប់ផ្នែកទាំងអស់នៃការកាត់ទោសរបស់អ្នក រួមទាំងរយៈពេលសាកល្បង ការដោះលែងមុនកំណត់ ឬលក្ខខណ្ឌ ផ្សេងៗទៀតដូចជា ការស្តារឡើងវិញជាដើម។

អ្នកអាចបោះឆ្នោតនៅពេលស្ថិតក្រោមការឃ្លាំមើលបានលុះត្រាតែថៅក្រោមមិនបានលុបចោលសិទ្ធិបោះឆ្នោតរបស់អ្នក។

## ចុះឈ្មោះបោះឆ្នោត

អ្នកត្រូវចុះឈ្មោះបោះឆ្នោតនៅអាសយដ្ឋានបច្ចុប្បន្នរបស់អ្នក។ ដើម្បីចុះឈ្មោះ ឬធ្វើបច្ចុប្បន្នកម្មបញ្ជី ឈ្មោះរបស់អ្នក សូមចូលទៅកាន់គេហទំព័រ mnvotes.gov។

### កាលបរិច្ឆេទឆ្នាំ 2022

**ការបោះឆ្នោតបឋម**
ថ្ងៃអង្គារ៍ទី9 ខែសីហា

**ការបោះឆ្នោតសម្រាប់ពលរដ្ឋអវត្តមាន**
បោះឆ្នោតតាមសំបុត្រ ឬដោយផ្ទាល់ថ្ងៃទី23 ខែកញ្ញា រហូតដល់ថ្ងៃទី7 ខែវិច្ឆិកា

**ចុះឈ្មោះបោះឆ្នោត**
ចុះឈ្មោះជាមុននៅត្រឹមថ្ងៃ ទី18 ខែតុលា ដើម្បីសន្សំ សំចៃពេលវេលានៅថ្ងៃ បោះឆ្នោត។

**ថ្ងៃបោះឆ្នោត**
ថ្ងៃអង្គារ៍ទី8 ខែវិច្ឆិកា

អ្នកក៏អាចចុះឈ្មោះនៅទីកន្លែងបោះឆ្នោតរបស់អ្នក នៅក្នុងថ្ងៃបោះឆ្នោតផងដែរ។ អ្នកត្រូវបង្ហាញភ័ស្តុតាង អំពីឈ្មោះ និងអាសយដ្ឋានបច្ចុប្បន្នរបស់អ្នក។ សម្រាប់ព័ត៌មានបន្ថែម សូមចូលទៅកាន់គេហទំព័រ mnvotes.gov ឬទូរស័ព្ទទៅលេខ 1-877-600-VOTE។

តទៅទំព័រក្រោយ...

# របៀបបោះឆ្នោត

VOTE 2022

.... តពីទំព័រមុខ

## សូមមើលសន្លឹកឆ្នោតគំរូរបស់អ្នក

ដើម្បីមើលបេក្ខជន និងសំណួរផ្សេងៗដែលនឹងមាន នៅលើសន្លឹកឆ្នោតរបស់អ្នកសូមចូលទៅកាន់វេបសាយត៍ mnvotes.gov។

## ទីតាំង និងពេលវេលាបោះឆ្នោត

ដើម្បីស្វែងរកទីកន្លែងបោះឆ្នោតរបស់អ្នក សូមចូល ទៅកាន់វេបសាយត៍ mnvotes.gov។ ទីកន្លែងបោះឆ្នោតភាគច្រើនបើកចាប់ពីម៉ោង 7 ព្រឹក ដល់ម៉ោង 8 យប់។

## ឯកសារយកទៅជាមួយ

ប្រសិនបើអ្នកបានចុះឈ្មោះបោះឆ្នោតនៅអាសយដ្ឋាន បច្ចុប្បន្នរបស់អ្នក អ្នកមិនចាំបាច់យកឯកសារ អត្តសញ្ញាណមកជាមួយឡើយ។ ប្រសិនបើអ្នកត្រូវការ ចុះឈ្មោះ ឬធ្វើបច្ចុប្បន្នកម្មបញ្ជីឈ្មោះរបស់អ្នក អ្នកត្រូវបង្ហាញភ័ស្តុតាងអំពីទីកន្លែងស្នាក់នៅមុនពេលអ្នកបោះឆ្នោត។ ដើម្បីទទួលបានព័ត៌មានបន្ថែម សូមចូលទៅកាន់វេបសាយត៍ mnvotes.gov ឬទូរសព្ទ ទៅលេខ1-877-600-VOTE។

## បោះឆ្នោតមុនពេលកំណត់ជាមួយនឹងសន្លឹកឆ្នោតសម្រាប់ពលរដ្ឋអវត្តមាន

អ្នកអាចបោះឆ្នោតមុនពេលកំណត់នៅការិយាល័យបោះឆ្នោតក្នុងមូលដ្ឋានរបស់អ្នកដោយចាប់ផ្តើមពីថ្ងៃសុក្រទី21 ខែកញ្ញា។ អ្នកក៏អាចដាក់ពាក្យស្នើសុំឱ្យបញ្ជូនសន្លឹកឆ្នោតសម្រាប់ពលរដ្ឋអវត្តមានតាមលិខិតផងដែរ។ ដើម្បីស្វែងរកការិយាល័យបោះឆ្នោតក្នុងមូលដ្ឋាន របស់អ្នក ឬដើម្បី ស្នើសុំសន្លឹកឆ្នោតសម្រាប់ពលរដ្ឋ អវត្តមាន សូមចូល ទៅកាន់វេបសាយត៍ mnvotes.gov។

### ការឈប់សម្រាកពីការងារដើម្បីទៅបោះឆ្នោត

អ្នកមានសិទ្ធិក្នុងការឈប់សម្រាកពីការងារដើម្បីទៅ បោះឆ្នោតដោយគ្មានការកាត់ប្រាក់បៀវត្សរ៍ ការឈប់ សម្រាប់ផ្ទាល់ខ្លួន ឬពេលវេលាវិស្សមកាល។

ការិយាល័យលេខាធិការរដ្ឋ *Minnesota*

*mnvotes.gov • 1-877-600-VOTE*